50

## សំណើ 50

វិសោធនកម្មនេះ បានស្នើឡើងដោយ វិសោធនកម្មរដ្ឋធម្មនុញ្ញព្រឹទ្ធសភា (Senate Constitutional Amendment) 17 នៃឆ្នាំ 2013–2014 សម័យធម្មតា (ជំណោះស្រាយជំពូក 127, លក្ខន្តិកៈនៃឆ្នាំ 2014) សំដែងការកែប្រែរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រនីញ៉ា ដោយការកែប្រែវគ្គដូចតទៅ; ដោយសារហេតុនេះ ប្រការដែលបានស្នើមានស្រាប់ហើយ ត្រូវបានលុបចោល បានផ្តិតជាប្រភេទ~~អក្សរគូសចោល~~ និងប្រការថ្មីដែលបានស្នើត្រូវបានថែម បានផ្តិតជាប្រភេទ*អក្សរផ្តេក* ដើម្បីបង្ហាញថាវាជាថ្មី។

### វិសោធនកម្មបានស្នើ ចំពោះវគ្គ 5 នៃមាត្រា IV

វគ្គ 5 នៃមាត្រា IV នោះបានកែដូចតទៅ ដើម្បីអានថា:

វគ្គ 5។ (a) *(1) វិមានអង្គនីតិបញ្ញត្តិនីមួយៗ* ត្រូវវិនិច្ឆ័យគុណសម្បត្តិ និងការបោះឆ្នោតនៃសមាជិករបស់ខ្លួន និងដោយការហៅបញ្ជីឈ្មោះ ឆ្នោតដែលបានបញ្ចូលទៅក្នុងព្រឹត្តិការណ៍រាល់ថ្ងៃ ~~ពីរ-ភាគបី~~ *ពីរ-ភាគបី* នៃសមាជិកភាពដែលមូលមតិគ្នា ដើម្បីបណ្តេញសមាជិក។

*(2) (A) វិមាននិមួយៗ អាចនឹងព្យួរសមាជិកបាន តាមញត្តិ ឬដំណោះស្រាយដែលបានអនុម័តយកតាមការហៅបញ្ជីឈ្មោះឆ្នោត បានបញ្ចូលទៅក្នុងព្រឹត្តិការណ៍រាល់ថ្ងៃ ពីរ-ភាគបី នៃសមាជិកភាពដែលមូលមតិគ្នា។ ញត្តិ ឬដំណោះស្រាយត្រូវមានការរកឃើញ និងការប្រកាស ដែលបានចែងមូលដ្ឋានសំរាប់ការព្យួរ។ ថ្វីបើមានប្រការផ្សេងទៀតនៃរដ្ឋធម្មនុញ្ញនេះក៏ដោយ គង់តែវិមានអាចនឹងចាត់ទុកថាប្រាក់ខែ និងអត្ថប្រយោជន៍របស់សមាជិក ត្រូវបានរឹបអូស សំរាប់ផ្នែកទាំងអស់ ឬខ្លះៗនៃរយៈពេលការព្យួរ ដោយប្រព្រឹត្តតាមប្រការនៃញត្តិ ឬដំណោះស្រាយ។*

*(B) សមាជិកដែលបានព្យួរ បានអនុលោមតាមឃ្លានេះ មិនត្រូវប្រើសិទ្ធិ ឯកសិទ្ធិ ភារៈកិច្ច ឬអំណាចនៃការិយាល័យរបស់គាត់ ឬប្រើធនធានអ្វីមួយ នៃអង្គនីតិបញ្ញត្តិ នៅក្នុងអំឡុងរយៈពេលនៃការព្យួរ មានប្រសិទ្ធិភាពឡើយ។*

*(C) ការព្យួរសមាជិក បានអនុលោមតាមឃ្លានេះ ត្រូវនៅមានប្រសិទ្ធិភាពដដែល រហូតដល់កាលបរិច្ឆេទបានបញ្ជាក់នៅក្នុងញត្តិ ឬដំណោះស្រាយ ឬបើមិនបានបញ្ជាក់កាលបរិច្ឆេទទេ នោះកាលបរិច្ឆេទជាបន្ទាប់មកនៃញត្តិ ឬដំណោះស្រាយ ដែលបញ្ចប់ការព្យួរត្រូវបានអនុម័តយកដោយការហៅបញ្ជីឈ្មោះឆ្នោត បានបញ្ចូលទៅក្នុងព្រឹត្តិការណ៍រាល់ថ្ងៃ ពីរ-ភាគបី នៃសមាជិកភាពដែលមូលមតិគ្នា។*

(b) គ្មានសមាជិកនៃអង្គនីតិបញ្ញត្តិណាម្នាក់ អាចនឹងទទួលយកប្រាក់សគុណឡើយ។ អង្គនីតិបញ្ញត្តិត្រូវអនុម័តច្បាប់ ដែលប្រតិបត្តិតាមអនុជំពូកនេះ។

(c) អង្គនីតិបញ្ញត្តិត្រូវអនុម័តច្បាប់ ដែលហាម ឬដាក់កំរិតតឹងរ៉ឹងពីការទទួលយកអំណោយ ដោយសមាជិកនៃអង្គនីតិបញ្ញត្តិ មកពីប្រភពណាមួយ បើការទទួលយកអំណោយ អាចនឹងបង្កើតនូវការប្រទាំងផលប្រយោជន៍។

(d) គ្មានសមាជិកនៃអង្គនីតិបញ្ញត្តិណាម្នាក់ ទទួលយកសំណងប្រាក់អ្វីដោយចេតនា សំរាប់ការបង្ហាញមុខ ការយល់ព្រមដើម្បីបង្ហាញមុខ ឬចាត់វិធានការអ្វីផ្សេងទៀត ក្នុងនាមនៃមនុស្សម្នាក់ទៀត នៅមុខគណៈរដ្ឋាភិបាលរដ្ឋ ឬភ្នាក់ងារណាមួយឡើយ។ បើសមាជិកទទួលយកសំណងប្រាក់អ្វីដោយចេតនា សំរាប់ការបង្ហាញមុខ ការយល់ព្រមដើម្បីបង្ហាញមុខ ឬចាត់វិធានការអ្វីផ្សេងទៀត ក្នុងនាមនៃមនុស្សម្នាក់ទៀត នៅមុខគណៈរដ្ឋាភិបាលមូលដ្ឋាន ឬភ្នាក់ងារណាមួយនោះ សំរាប់រយៈពេលមួយឆ្នាំ បន្ទាប់ពីការទទួលយកសំណងប្រាក់ សមាជិកនោះមិនអាចបោះឆ្នោត ឬធ្វើ ឬមិនអាចចូលរួមធ្វើ ឬប៉ុនប៉ងក្នុងរបៀបណាមួយ ដើម្បីប្រើតំណែងផ្លូវការរបស់គាត់ ដើម្បីមានអានុភាពលើអំពី ឬការសំរេចនៅមុខអង្គនីតិបញ្ញត្តិ ក្រៅពីអំពី ឬការសំរេចជាប់ទាក់ទងនឹងកម្រងច្បាប់ ដែលបានរៀបរាប់ក្នុងអនុជំពូក (c) នៃវគ្គ 12 ~~នៃមាត្រានេះ~~ ដែលគាត់មានចេតនា ឬមានមូលហេតុត្រូវដឹង នឹងមានឥទ្ធិពលហិរញ្ញវត្ថុដោយផ្ទាល់ និងខ្លាំងក្លា ទៅលើមនុស្សនោះ ហើយនឹងពុំមានឥទ្ធិពលទៅលើសាធារណជនទូទៅ ឬផ្នែកសំខាន់ៗនៃសាធារណៈ ក្នុងលក្ខណៈដែលស្រដៀងគ្នា។ ដូចបានប្រើក្នុងអនុជំពូកនេះ ពាក្យ “សាធារណជនទូទៅ” រួមមាននូវ ឧស្សាហកម្ម ពាណិជ្ជកម្ម ឬវិជ្ជាជីវៈ។ តែជាយ៉ាងណាមិញ សមាជិកអាចនឹងចូលប្រឡូកក្នុងសកម្មភាពដែលទាក់ទងនឹងគណៈ ឬភ្នាក់ងារ ដែលកំរិតទៅលើនាមរបស់គាត់ ដែលបង្ហាញក្នុងសមត្ថភាពជាមេធាវីនៅមុខតុលាការណាមួយ ឬគណៈឧទ្ធរសំណងប្រាក់ឲ្យកម្មករ (Workers’ Compensation Appeals Board) ឬប្រព្រឹត្តជាអ្នកគាំពារ ដោយគ្មានសំណងប្រាក់ ឬធ្វើការសាកសួរព័ត៌មាន ក្នុងនាមនៃមនុស្សម្នាក់ នៅមុខគណៈ ឬភ្នាក់ងារ។ អនុជំពូកនេះ មិនហាមឃាត់អំពើអ្វីមួយនៃភាពជាដៃគូ ឬក្រុមហ៊ុន ដែលសមាជិកគឺជាសមាជិកម្នាក់ បើសិន សមាជិកនោះ មិនចែកដោយផ្ទាល់ ឬមិនដោយផ្ទាល់ នៅក្នុងថ្លៃឈ្នួល ដកការចំណាយអ្វីមួយដែលសន្មត់ថាជារបស់ថ្លៃឈ្នួលនោះ ដែលបណ្តាលមកពីអំពីនោះ។

(e) អង្គនីតិបញ្ញត្តិត្រូវអនុម័តច្បាប់ ដែលហាមឃាត់សមាជិកនៃអង្គនីតិបញ្ញត្តិ ដែលអាណត្តិការិយាល័យរបស់គេ ចាប់ផ្តើមនៅចំ ឬបន្ទាប់ពីថ្ងៃទី 3 ខែធ្នូ 1990 ចេញពីការបញ្ចុះបញ្ចូល សំរាប់សំណងប្រាក់ ដូចបានគ្រប់គ្រងដោយ ក្រឹត្យកែទំរង់នយោបាយ (Political Reform Act) នៃឆ្នាំ 1974 នៅមុខអង្គនីតិបញ្ញត្តិចំនួន 12 ខែបន្ទាប់ចាកចេញពីការិយាល័យ។

(f) អង្គនីតិបញ្ញត្តិត្រូវអនុម័តច្បាប់ថ្មី និងពង្រឹងការប្រតិបត្តិច្បាប់ដែលមានស្រាប់ ហាមឃាត់សមាជិកនៃអង្គនីតិបញ្ញត្តិ ពីការចូលប្រឡូកក្នុងសកម្មភាព ឬការមានចំណង់ ដែលប្រទាំងជាមួយការលាចាកភារៈកិច្ច និងការទទួលខុសត្រូវរបស់គេដ៏ត្រឹមត្រូវ។ តែជាយ៉ាងណាមិញ ប្រជាជនរក្សាអំណាចរបស់គេ ដើម្បីប្រតិបត្តិតាមការតម្រូវនេះ ដោយអនុលោមតាមមាត្រា II។